# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣
# Situation Room on Cambodia Election Day 2013

## សេចក្តីថ្លែងការណ៍រួម
## ស្តីពី
## ការវាយតម្លៃលើ កិច្ចព្រមព្រៀងដំណោះស្រាយនយោបាយ រវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ និងអនុសាសន៍លើការអនុវត្តន៍កិច្ចព្រមព្រៀង

ភ្នំពេញ, ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៤

បន្ទប់ស្ថានការណ៍នៃអង្គការសង្គមស៊ីវិលនៅកម្ពុជា យល់ឃើញថា កិច្ចព្រមព្រៀងជាបន្តបន្ទាប់នៃថ្នាក់ដឹកនាំកំពូល និងគណៈកម្មាធិការចម្រុះ ពិសេសកិច្ចព្រមព្រៀងថ្ងៃទី ២២ កក្កដា ឆ្នាំ២០១៤ ស្តីពីដំណោះស្រាយនយោបាយ រវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ គឺជា**ចំណុចចាប់ផ្តើមដ៏មានសារៈសំខាន់ដើម្បីឈានទៅរកកំណែទម្រង់ប្រកបដោយការយោគយល់គ្នា** ដើម្បីពង្រឹងដំណើរការបោះឆ្នោត និងប្រជាធិបតេយ្យ។ កិច្ចព្រមព្រៀងនោះក៏បានបន្ថយស្ថានភាពតានតឹង និងបញ្ចប់បញ្ហាជាប់គាំងនយោបាយដែលបានផ្តល់ផលអវិជ្ជមានដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងសក្តានុពលសេដ្ឋកិច្ច នៅកម្ពុជាក្រោយការបោះឆ្នោត។

បន្ទប់ស្ថានការណ៍នៃអង្គការសង្គមស៊ីវិលនៅកម្ពុជាយល់ឃើញថា ខ្លឹមសារនៃកិច្ចព្រមព្រៀងទាំងនោះនៅមិនទាន់លំអិតច្បាស់លាស់នៅឡើយ ដែលអាចនាំមកនូវហានិភ័យក្នុងការបកស្រាយ និងការអនុវត្តន៍កិច្ចព្រមព្រៀងទាំងនោះ។ ឯកសារលំអិត ឬការប្រព្រឹត្តិទៅនូវកំណែទម្រង់សំខាន់ៗរួមមាន កំណែទម្រង់បោះឆ្នោត និងស្ថាប័នរៀបចំការបោះឆ្នោត និងតុល្យភាពអំណាចនៅក្នុងរដ្ឋសភា មិនត្រូវបានចែង ឬភ្ជាប់ក្នុងកិច្ចព្រមព្រៀងនោះនៅឡើយ។

បន្ទប់ស្ថានការណ៍នៃអង្គការសង្គមស៊ីវិលនៅកម្ពុជា អំពាវនាវឲ្យរាជរដ្ឋាភិបាល និងគណបក្សកាន់អំណាចបញ្ឈប់ការប្រើប្រស់ស្ថាប័នរដ្ឋ ស្ថាប័នតុលាការ អាជ្ញាធរ និងកងកម្លាំងសន្តិសុខ ដើម្បីបំរើផលប្រយោជន៍នយោបាយដែលហួសពីដែនកំណត់នៃក្របខ័ណ្ឌរដ្ឋធម្មនុញ្ញ និងច្បាប់។ រាជរដ្ឋាភិបាលត្រូវបើកទីលានប្រជាធិបតេយ្យឡើងវិញដោយគ្មានលក្ខ័ណ្ឌខាងនយោបាយ ដើម្បីស្តារឡើងវិញនូវសិទ្ធិសេរីភាពបញ្ចេញមតិរបស់ប្រជាពលរដ្ឋ

ដែលជាសេរីភាពមូលដ្ឋាន និងបាតគ្រឹះនៃលទ្ធិប្រជាធិបតេយ្យ។ ជាមួយគ្នានេះ ដើម្បីស្តារឡើងវិញនូវនីតិរដ្ឋដែលអនុវត្តច្បាប់ត្រឹមត្រូវ គណបក្សទាំងពីរត្រូវធានាឲ្យបាននូវឯករាជ្យស្ថាប័នតុលាការ និងស្ថាប័នរដ្ឋនានា ដោយពិនិត្យ និងពិភាក្សាឡើងវិញលើច្បាប់សំខាន់ដូចជា ច្បាប់ចំនួនបីពាក់ព័ន្ធនឹងវិស័យតុលាការ ដោយពិចារណាលើអនុសាសន៍របស់ អង្គការសង្គមស៊ីវិល និងអ្នកជំនាញការអន្តរជាតិដែលធ្លាប់បានផ្តល់នាពេលកន្លងមក។

បន្ទប់ស្ថានការណ៍នៃអង្គការសង្គមស៊ីវិលនៅកម្ពុជា អំពាវនាវឲ្យគណបក្សទាំងពីរក៏ត្រូវអនុវត្តតាមស្មារតីនៃកិច្ចព្រមព្រៀង១៨ចំណុច ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤ រួមបញ្ចូលទាំងកំណែទម្រង់ការបោះឆ្នោតរើសមេភូមិ និងការបង្កើតច្បាប់ស្តីពីហិរញ្ញវត្ថុគណបក្សនយោបាយ ដែលគណបក្សទាំងពីរធ្លាប់បានព្រមព្រៀងគ្នាក្នុងការចរចានាពេលកន្លងមក។ ដើម្បីផ្តល់ទំនុកចិត្តដល់ប្រជាពលរដ្ឋក្នុងការអនុវត្តន៍កិច្ចសន្យា គណបក្សទាំងពីរត្រូវដាក់ចេញនូវផែនការសកម្មភាព និងកំណត់កាលបរិច្ឆេទនៃលទ្ធផលសំរេចនៃកំណែទម្រង់ដែលចែងក្នុងកិច្ចព្រមព្រៀងទាំងនោះឲ្យបានជាក់លាក់។ បន្ទប់ស្ថានការណ៍នៃអង្គការសង្គមស៊ីវិលនៅកម្ពុជា សូមចូលរួមផ្តល់អនុសាសន៍ពាក់ព័ន្ធនឹងការកំណែទម្រង់សំខាន់ៗ ៖

- គណៈកម្មាធិការចម្រុះនៃគណបក្សទាំងពីរ ត្រូវចែងលំអិតអំពីការប្រព្រឹត្តិទៅនៃកំណែទម្រង់សំខាន់ៗ រួមមាន កំណែទម្រង់បោះឆ្នោត និងស្ថានប័នរៀបចំការបោះឆ្នោត និងតុល្យភាពអំណាចនៅក្នុងរដ្ឋសភា ដោយផ្អែកលើកិច្ចព្រមព្រៀងទាំងនោះ។
- ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ត្រូវសម្រេចបានយ៉ាងយូរត្រឹមខែវិច្ឆិកា ឆ្នាំ២០១៤។
- ការធ្វើវិសោធនកម្មច្បាប់បោះឆ្នោត និងការបង្កើតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**ថ្មីមួយ**ត្រូវសម្រេចឲ្យបានស្របតាមស្មារតីនៃកិច្ចព្រមព្រៀងយ៉ាងយូរត្រឹមចុងឆ្នាំ២០១៤ ដើម្បីឲ្យគណកម្មាធិការថ្មីមួយនេះមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត។
- ការបង្កើតបញ្ជីឈ្មោះបោះឆ្នោត**ថ្មីមួយ**ដែលត្រូវបានបង្កើត តាមរយៈការផ្លាស់ប្តូរប្រព័ន្ធចុះឈ្មោះបោះឆ្នោតត្រូវសម្រេច យ៉ាងយូរត្រឹមដើមឆ្នាំ២០១៦សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតបន្ទាប់។

បន្ទប់ស្ថានការណ៍នៃអង្គការសង្គមស៊ីវិលអំពាវនាវ ដល់សហគមន៍អន្តរជាតិ និងដៃគូអភិវឌ្ឍន៍ចូលរួមឃ្លាំមើលយ៉ាងសកម្ម និងជម្រុញការអនុវត្តន៍កំណែទម្រង់នៃកិច្ចព្រមព្រៀងទាំងនោះក្នុងការធានាឲ្យបាន ការគោរពតាមគោលការណ៍ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។

បន្ទប់ស្ថានការណ៍នៃអង្គការសង្គមស៊ីវិលមានមោទនភាពជាប្រវត្តិសាស្ត្រ ចំពោះការចូលរួមរបស់ខ្លួនឃ្លាំមើលតស៊ូមតិ និងផ្តល់អនុសាសន៍ក្នុងដំណើរការថ្ងៃបោះឆ្នោតឆ្នាំ២០១៣ និង ក្រោយពេលបោះឆ្នោតដែលបាននាំមកនូវដំណើរការ រដ្ឋសភាដែលនឹងមានពហុបក្ស និងការសន្យាកំណែទម្រង់ដើម្បីពង្រឹងដំណើរការប្រជាធិបតេយ្យ និងការបោះឆ្នោត។

បន្ទប់ស្ថានការណ៍នៃអង្គការសង្គមស៊ីវិលបានសន្មតការបញ្ចប់បេសកម្មរបស់ខ្លួនចាប់ពីពេលថ្ងៃនេះតទៅ។ សម្ព័ន្ធកំណែទម្រង់បោះឆ្នោត (ERA) ក្រុមការងារនៃអង្គការសង្គមស៊ីវិល និងវេទិកាមួយចំនួននឹងបន្តបេសកម្មដើម្បីចូលរួមពង្រឹងការអនុវត្តន៍នៃកិច្ចព្រមព្រៀងនយោបាយទាំងនោះ និងលើកស្ទួយការបង្រួបបង្រួម និងផ្សះផ្សាជាតិ ព្រមទាំងចូលរួមការលើកកម្ពស់ការគោរព និងការពារសិទ្ធិមនុស្ស ប្រជាធិបតេយ្យ និងការអភិវឌ្ឍន៍ជាតិប្រកបដោយនិរន្តរភាព។

**<u>ព័ត៌មានបន្ថែមសូមទាក់ទង៖</u>**

| | | |
|---|---|---|
| ១.លោក នី ចរិយា | ប្រធានផ្នែកស៊ើបអង្កេតនៃសមាគម ADHOC | ០១១ ២៧ ៩៩ ៥៩ |
| ២.លោកស្រី រស់ សុភាព | នាយិកាអង្គការ GADC | ០១២ ៦២ ៧៨ ៥៧ |
| ៣.លោក សុក សំអឿន | ប្រធានសម្របសម្រួលនៃ CHRAC | ០១២ ៩០ ១១ ៩៩ |
| ៤.លោក តឹក វណ្ណារ៉ា | នាយកប្រតិបត្តិ NGO Forum | ០១២ ៧៩ ៣៤ ៨៩ |
| ៥.លោក សៀង សារឿន | នាយកប្រតិបត្តិអង្គការ CCC | ០១៦ ៩០ ០៥ ០៣ |
| ៦.លោក សួន ប៊ុនស័ក្តិ | អគ្គលេខាធិការនៃ CHRAC | ០៩២ ៣៤ ៤៣ ៥៧ |
| ៧.លោក យ៉េង វីរៈ | នាយកប្រតិបត្តិអង្គការ CLEC | ០១២ ៨០ ១២ ៣៥ |
| ៨.លោក យ៉ង់ គិមអេង | នាយកប្រតិបត្តិ PDP-Center | ០១៦ ៨២ ៨២ ១១ |
| ៩.លោក ព្រាប កុល | នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា | ០១២ ៨៧ ៧៨ ៣៣ |
| ១០.លោកស្រី ធីតា ឃឹះ | នាយិកាអង្គការសីលការ | ០១២ ៨៣ ៨៤ ៦៤ |
| ១១.លោក ម៉ម សម្បត្តិ | នាយកប្រតិបត្តិ DPA | ០១២ ៧៧ ៩៧ ៣៤ |
| ១២.លោក ជាង សុខា | នាយកប្រតិបត្តិអង្គការ YRDP | ០១២ ៣៦ ០៤ ៦៤ |
| ១៣.លោក ណែប ស៊ិនថៃ | នាយក API | ០១២ ៥២ ៧០ ០៤ |
| ១៤.លោក គល់ បញ្ញា | នាយកប្រតិបត្តិអង្គការខុមហ្វ្រែល | ០១២ ៩៤ ២០ ១៧ |
| ១៥.លោក ហុង គឹមសួន | ប្រធានសម្ព័ន្ធ CISA | ០១២ ៩៤ ៥៥ ០៥ |
| ១៦.លោក ឈួន បូរិត | នាយកប្រតិបត្តិ KYSD | ០១២ ៧៩ ៨៤ ៨៨ |
| ១៧.លោក សុខ ពិទូរ្យ | នាយកប្រតិបត្តិក្រុមប្រឹក្សាយុវជនកម្ពុជា | ០១៧ ២៧ ៣៣ ០៣ |